Reçu le 20-1-50
INDOCHINE FRANÇAISE — RÉGIE DU DÉPÔT LÉGAL

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយជំនឿខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកជំនឿសាសនាៈ ព្រះទេពសត្ថា ហួរ-ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

| ផ្នែកអក្សរសាស្ត្រ | បញ្ជីរឿង | ទំព័រ |
|---|---|---|
| លោក ឈឿង-កុល | រឿងអតិបារិណីយក្ខិនី .................... | ៦៤១ |
| មហា ទម-ណាត្រី | និទានសុភាសិត .......................... | ៦៥៦ |
| លោក អ៊ូ-គូ | របររកស៊ីយកឃ្មុំ ក្នុងរសាងភ្នំ ឬរូងជ្រោះភ្នំ..... | ៦៦៤ |
| លោក ភិយ-ប៊ុក ក្រមការ | សុភាសិតខ្មែរភាគទី ២ (តមក)............. | ៦៧២ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម | ស័ព្ទបារាំងប្រែជាខ្មែរ (តមក) .............. | ៦៧៩ |
| — | ប្រវត្តិសាស្ត្រសង្ខេប ប្រទេសឥណ្ឌៀ (តមក) .. | ៦៨២ |
| អ្នកឧកញ៉ា នូ-កន | រឿងសាមកុក (តមក) ..................... | ៦៨៩ |

ផ្នែកសាសនា

| | | |
|---|---|---|
| ព្រះទេពមុនី យូរ-ប៊ុណ្ណ | បធានកថា.................................. | ៦៩៦ |

កំណត់ទីនីប្រវត្តិការណ៍

| | | |
|---|---|---|
| លោកមហា ឈិន | ពិធីបុណ្យសម្ពោធសាលាធម្មវិន័យ.......... | ៧០១ |
| ក្រសួងធម្មការ | បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី (តមក)... | ៧០៧ |

ឆ្នាំទី ២១ — លេខ ៩ ខែ កញ្ញា ឆ្នាំ ១៩៤៩ — ដំឡៃជាវ ១ ឆ្នាំ ៩៦ រៀល ។

Septembre

# បធានកថា

## របស់ព្រះទេពមុនី យូរ ប៉ុណ្ណ

**នៅវត្តខណ្ឌលោម**

*ជាក្រុមជំនុំព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ*

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការចំពោះព្រះអរហំសម្មាសម្ពុទ្ធដ៏មានជោគព្រះអង្គនោះ (ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ ដោយសេចក្ដីគោរព) ។

វេលានេះ នឹងសំដែងអំពីបធានកថា ដើម្បីជាពន្លឺដល់ពុទ្ធសាសនិកជនទាំងឡាយក្នុងពុទ្ធសាសនមណ្ឌលដូចតទៅនេះ ។

បធានៈ ប្រែថាសេចក្ដីព្យាយាម គឺព្យាយាមញុំាងសាធារណៈប្រយោជន៍ទាំងបច្ចុប្បន្ន ទាំងបរលោក ឬញុំាងប្រយោជន៍ផ្ទាល់ខ្លួនមួយ ៗ ឲ្យកើតឲ្យមានឡើង ហៅថាបធានៈ ។

ឯពាក្យដែលជាវេវចនៈនឹងបធានៈនោះ មានច្រើនប្រភេទណាស់ ដូចពាក្យថា វិរិយៈ ប្រែថាសេចក្ដីអង់អាច មានតេជានុភាព អាចបានពុះពារបំពេញប្រយោជន៍ឲ្យសម្រេចដល់ទីបំផុត ។ បរក្កមៈ ប្រែថាមានដំណើរទៅមុខមិនរួញរា បើទុកជាមាន ឧបសគ្គៈ មកកាលណា ៗ ក៏មិនរំភើប ញាប់ញ័រ តក់ស្លុតឡើយ ។ ឧស្សាហៈ ប្រែថាមានសេចក្ដីអត់ធន់ទ្រាំទ្រតស៊ូ ឧហាត់សង្វាតធ្វើកិច្ចការគ្រប់យ៉ាង ។

ឧដ្ឋានៈ ប្រែថាលះបង់នូវសេចក្ដីខ្ជិលច្រអូស ហើយក្រោកឡើងស្រែក ចាប់ការងារតត់ផុញទ្រាន់ ៗ អាតប្បៈ ប្រែថាដុតកំដៅ ឬកំចាត់ កន្ទ្រាក់នូវវត្ថុដែលនាំឲ្យសៅហ្មងចេញផុតអំពីសន្ដានចិត្ត ។ ធិតិ ប្រែថា មានសេចក្ដីខ្ជះខ្ជែងយ៉ាងម៉ឺងម៉ាត់ចំពោះកិច្ចការសព្វយ៉ាង ។ អដ្ឋិតិ ប្រែថាអំពើណាមួយដែលកើតឡើងត្រូវកាលត្រូវទំនង ហើយមិនការង មិនអល់អែក ធ្វើអំពើនោះភ្លាម ៗ មិនឲ្យកន្លងពេល ។ អប្បដិវានី ប្រែថាបើមានធ្វើកិច្ចការណាមួយមិនទាន់បានសម្រេចទេ មិនថយក្រោយ មិនលះបង់ចោលនូវកិច្ចការនោះឡើយ ។

ពាក្យដែលបានពោលមកទាំងប៉ុន្មាននេះ ផ្សេងគ្នាតែព្យញ្ជនៈឯសេចក្ដីអធិប្បាយ មានដំណើរស្រប់គ្នា រួមមកបានសេចក្ដីថាព្យាយាមដូចគ្នាទាំងអស់ ។

បធានៈនោះមាន ៤ យ៉ាងគឺ :

១ — **សំវរប្បធាន** ព្យាយាមក្នុងការប្រយ័ត្នមិនឲ្យបាបកើតឡើងបាន ។

២ — **បហានប្បធាន** ព្យាយាមក្នុងការលះបង់នូវបាបដែលកើតឡើងហើយ ឲ្យវិនាសទៅវិញ ។

៣— **ភាវនាប្បធាន** ព្យាយាមក្នុងការធ្វើកុសលឲ្យកើតឡើង ។

៤ — អនុរក្ខណប្បធាន ព្យាយាមក្នុងការរក្សាកុសលដែលកើតឡើងហើយ ឲ្យរឹតតែចំរើនឡើង ។

បធាន: ទាំង ៤ យ៉ាងនេះ បើសំដែងរួបរួមដោយកិច្ចមាន ២ យ៉ាងគឺ:

១ — បហានកិច្ច កិច្ចដែលត្រូវលះបង់ ។

២ — ភាវនាកិច្ច កិច្ចដែលត្រូវចំរើន ។

អធិប្បាយថា: បហានកិច្ច កិច្ចដែលត្រូវលះបង់នោះគឺលះបង់នូវអំពើបាប ; ពាក្យថាបាប សំដៅយកអំពើអាក្រក់ ៣ យ៉ាងគឺ កាយកម្ម ៣ វចីកម្ម ៤ មនោកម្ម ៣ ; កម្មដ៏លាមកទាំង ៣ នេះ សុទ្ធតែចាត់ជាបាបទាំងអស់ ។ គន្ថបាលីមានសំដែងអំពីបាប ៣ ពួកនេះច្រើនជាងចំណែកដទៃ ៗ ព្រោះបាបទាំងអម្បាលនេះ ជាប្រធានរបស់បាបទាំងពួង; សូម្បីបាបដទៃៗ ក៏រួមចូលគន្ថបាប ៣ ពួកនេះដែរ; បាបទាំងនេះជួនកាលហៅថាបាបដដែល ប្រែថាកម្មដ៏លាមក, ជួនកាលហៅថាទុច្ចរិត ប្រែថាការប្រព្រឹត្តិអាក្រក់ , ជួនកាលហៅថាអកុសល ប្រែថាអំពើមិនល្អ , ជួនកាលហៅថា អករណីយកិច្ច ប្រែថាកិច្ចមិនគួរធ្វើ, ជួនកាលហៅថា អធម្ម-ចរិយៈ វិសមចរិយៈ ប្រែថាការប្រព្រឹត្តិមិនជាធម៌ ការប្រព្រឹត្តិមិនសម ។

បណ្តាបាបទាំងប៉ុន្មានដែលបានពោលមកនេះ ឥតមានចំណែកណាមួយដែលជារបស់គួរធ្វើ គួរប្រព្រឹត្តសោះឡើយ សុទ្ធតែជាកិច្ចមិនគួរធ្វើ មិនគួរប្រព្រឹត្តទាំងអស់ ។ សមដូចព្រះភគវន្តមុនី ទ្រង់ត្រាស់ទីងព្រះ-

អានន្ទថា ឯកំសេនាហំ អានន្ទ អករណីយំ វទាមិ ម្នាលអានន្ទ តថាគត ហៅកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ជាកិច្ចដែលបុគ្គលមិនគួរធ្វើដោយដាច់ខាត; កាលបើបុគ្គលណាមួយប្រើកាយ វាចា ចិត្ត ធ្វើអករណីយ-កិច្ចនោះហើយ ត្រូវដឹងខ្លួនចុះថាមុខជានឹងមានទោសពុំខាន ។

ឯទោសប្រព្រឹត្តទុច្ចរិតនោះមាន ៥ យ៉ាងគឺ:

១ — អត្តាបិ អត្តានំ ឧបវទតិ សូម្បីខ្លួនឯងក៏តិះដៀលខ្លួនឯងដែរ ។

២ — អនុវិច្ច វិញ្ញូ គរហន្តិ លោកអ្នកចេះដឹងរិះគន់មើលរមែងតិះដៀលបាន ។

៣ — បាបកោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ កេរ្តិ៍ឈ្មោះអាក្រក់ រមែងល្បីខ្ចរខ្ចាយទៅសព្វទិស ។

៤ — សម្មូឡ្ហោ កាលំ ករោតិ រវើងភ្លេចស្មារតីក្នុងពេលដែលទៀបស្លាប់ ។

៥ — កាយស្ស ភេទា បរម្មរណា ទុគ្គតឹ ឧបបជ្ជតិ ខាងមុខអំពីទំលាយខ្លួនទៅ រមែងទៅកើតក្នុងទុគ្គតិ ។

បុគ្គលណាធ្វើបាបដូចបានពោលមកនេះ រមែងក្តៅក្រហាយក្នុងលោកទាំងពីរ គឺៈក្នុងលោកនេះ រមែងក្តៅក្រហាយដោយគិតថា អាត្មាអញធ្វើបាបផ្សេងៗ, លុះច្យុតចាកលោកនេះទៅហើយរឹតតែក្តៅក្រ-

ហាយផាន់នេះទៅទៀត ។ ព្រោះហេតុនោះបានជាព្រះអរហំសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា បាបនេះជាអំពើមិនគួរធ្វើ មិនគួរប្រព្រឹត្តឡើយ, នេះហៅថា បហានកិច្ច ។

ការនាកិច្ច កិច្ចដែលគួរចំរើននោះ គឺកម្មដែលកំចាត់បង់នូវសេចក្តីអាក្រក់ហៅថាកុសល ការដែលព្យាយាមធ្វើកុសលឲ្យកើតឲ្យមានឡើងហៅថាបំពេញកុសលឲ្យបរិបូណ៌, កុសលនេះប្រែបចាផ្កាតកាន់វៃ បុនប្រសប់ទាន់ៗបាយធ្វើឲ្យផុះផាល ឲ្យល្អគណៈសបំរើនឡើងនូវគោតសម្បូទបំណោះវ៉ាតាំងនូវលោកនូវធម៌ ។ កុសលនោះ បើសំដែងដោយបុសគល់បានទាន់អលោភោ មិនជំពាក់ចិត្តនឹងទ្រព្យសម្បត្តិ មិនចង់បាននូវទ្រព្យសម្បត្តិរបស់អ្នកដទៃ គឺមិនលួចលាក់ឆក់ដណ្តើមបំបាត់ប្រវ័ញ្ច សង្កត់សង្កិនរបបាន់យកទ្រព្យសម្បត្តិរបស់អ្នកដទៃ ។ អទោសោ មិនប្រទូស្តមិនខឹងមិនរករឿងរកហេតុអ្នកដទៃ ឲ្យផល់នូវសេចក្តីវិនាស ។ អមោហោ មិនវង្វេងភ្លេចស្មារតីដោយអ្នកដទៃគេគម្រាមកំហែង បំភាន់គំនិតជាដើមឡើយ ។

មួយទៀត កុសលនេះបើសំដែងដោយទីកើតមាន ១០ ប្រការ គឺ

១ – ការឲ្យនូវវត្ថុដ៏គួរដល់បុគ្គលដែលគួរឲ្យដោយសេចក្តីសង្គ្រោះ បូជាគុណ មានឲ្យដល់មនុស្សកំសត់ បូជាដល់លោកអ្នកមានសីលធម៌ និងមាតាបិតាជាដើម ហៅថាទានៈ ។

២ – ការវៀរចាកអំពើអាក្រក់ដែលកើតអំពីកាយវាចា មានវៀរបញ្ចវេរជាដើម ហៅថាសីលៈ ។

៣ – ការធ្វើចិត្តឲ្យស្ងប់រម្ងាប់ចាកអកុសលធម៌ មាននីវរណធម៌ជាដើម ដោយសមថវិធី និងវិបស្សនាវិធី ហៅថាភាវនា ។

៤ – ការទំរុះទំលាយអស្មិមានៈ ដែលកើតមានក្នុងចិត្តដោយសេចក្ដីកោតក្រែងចំពោះបុគ្គលដែលគួរកោតក្រែង គឺជនដែលចំរើនដោយជាតិដោយវ័យ ដោយគុណ ហៅថាអបចាយនៈ ។

៥ – ការជួយខ្វល់ខ្វាយក្នុងកិច្ចការកុសល ហៅថាវេយ្យាវច្ចៈ ។

៦ – ការឲ្យនូវចំណែកបុណ្យ ដែលខ្លួនបានធ្វើហើយដល់អ្នកដទៃ ដោយមេត្រីចិត្ត ដើម្បីឲ្យគេត្រេកអរតាម ហៅថាបត្តិទានៈ ។

៧ – ការអនុមោទនាត្រេកអរតាមនូវសេចក្ដីល្អ របស់អ្នកដទៃ ដែលគេបានធ្វើហើយ ដោយចិត្តដែលប្រាសចាកសេចក្ដីច្រណែនឈ្នានិស ហៅថាបត្តានុមោទនា ។

៨ – ការណែនាំបង្ហាត់បង្រៀនប្រៀនប្រដៅអ្នកដទៃឲ្យចេះចំណេះវិជ្ជាដែលឥតទោស ឬពន្យល់ប្រាប់ក្នុងផ្លូវលោកផ្លូវធម៌ ឲ្យស្គាល់កិច្ចគួរធ្វើនិងមិនគួរធ្វើ ដែលប្រព្រឹត្តទៅដើម្បីសេចក្ដីសុខ-ចំរើនក្នុងបច្ចុប្បន្ននេះ រហូតដល់សម្បត្តិសួគ៌សម្បត្តិព្រះនិព្វានជាទីបំផុត ហៅថាធម្មទេសនា ។

៩ — ការតាំងចិត្តស្តាប់ធម៌ ស្តាប់ពាក្យទូន្មាន ពាក្យរៀនប្រដៅ ដោយប្រុងឲ្យចេះចាំស្ទាត់ ធ្វើកើត និយាយបាន ហៅថាធម្មស្សវនៈ ។

១០ — ការធ្វើទិដ្ឋិគឺសេចក្តីយល់ឃើញរបស់ខ្លួនឲ្យត្រូវតាមគន្លងធម៌ដែលពិតមែន ហៅថាទិដ្ឋុជុកម្មៈ ។

អំពើទាំង ១០ ប្រការនេះ ហៅថាបុញ្ញកិរិយាវត្ថុ គឺជាទីកន្លែងសម្រាប់កើតបុណ្យ ។ បុគ្គលណាបានធ្វើកុសលដូចបានពោលមកនេះ បុគ្គលនោះរមែងបាននូវអានិសង្ស ៥ យ៉ាង គឺ

១ — អត្តាបិ អត្តានំ ន ឧបវទតិ សូម្បីខ្លួនឯងក៏តិះដៀលខ្លួនឯងមិនបាន ។

២ — អនុវិច្ច វិញ្ញូ បសំសន្តិ អ្នកប្រាជ្ញទាំងឡាយលោកឃើញតាមការពិត លោករមែងសរសើរ ។

៣ — កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ មានកិត្តិស័ព្ទពីរោះល្បីខ្ចរខ្ចាយទៅសព្វទិស ។

៤ — អសម្មូឡ្ហោ កាលំ ករោតិ មិនវង្វេងភ្លេចស្មារតីធ្វើមរណកាល ។

៥ — សុគតិំ សគ្គំ លោកំ ឧបបជ្ជតិ នឹងទៅកើតក្នុងសុគតិ គឺស្ថានសួគ៌ និងមនុស្សលោក ។

អានិសង្សទាំង ៥ យ៉ាងនេះ រមែងមានដល់បុគ្គលអ្នកមានសេចក្តី

ព្យាយាមបំពេញសុចរិតធម៌. ហើយឲ្យសង្ឃឹមទុកចិត្តចុះ ថាមុខជានឹងជួបប្រទះនូវសេចក្ដីសុខ - ចំរើនក្នុងលោកនេះ នឹងលោកខាងមុខមិនខាន នេះហៅថាការនាកិច្ច ។

កិច្ចទាំងពីរយ៉ាងនេះ ជាដំណើរខាងផ្លូវធម៌; បើជាខាងផ្លូវលោកវិញ សំដៅយកការលះបង់នូវបុគ្គល មារយាទអាក្រក់ ក្រអឺតក្រអោង កោងកាចខ្ជិលច្រអូស ដើរលេងស៊ីផឹក ចាយវាយទ្រព្យសម្បត្តិឥតប្រ-យោជន៍ ឥតសណ្ដាប់ធ្នាប់ មានផ្លូវពោរកម្លុចបុះចក់ដណ្ដើម រឹបជាន់សង្កត់សង្កិនយកផលជានអ្នកដទៃជាដើម ។ អំពើទាំងអស់នេះ សុទ្ធតែជាអំពើនាំឲ្យថោកទាប ទន់ខ្សោយកាប់ស្ពឹកដល់ខ្លួនឯង នឹងប្រទេសជាតិមាតុភូមិ ជាអំពើនាំឲ្យលោកតិះដៀល: បុគ្គលអ្នកស្រឡាញ់សេចក្ដីល្អត្រូវលះបង់ចោល ។

យើងកើតមកជាមនុស្សម្នាក់ៗ ក្នុងលោកសន្និភាសនេះ: មានអវយវៈគ្រប់គ្រាន់ មិនវិកលវិការ: ដោយកាយគនៈណាមួយ ត្រូវតែបំពេញកិច្ចរបស់ខ្លួនឲ្យគ្រប់គ្រាន់ កុំពឹងផ្អែកទៅលើរូបបុគ្គលណាមួយឲ្យគេចិញ្ចឹមខ្លួនដោយងាយ ៗនោះ មិនបានសម្រេចប្រយោជន៍ប៉ុន្មានទេ, ព្រោះរូបនិមួយៗ សុទ្ធតែមានសេចក្ដីសុខទុក្ខជាប់ទាក់ទងដោយរាងកាយ ឬក៏មានរាងកាយជាទីអាស្រ័យនៅនៃសេចក្ដីសុខទុក្ខ ដូចជាគេហដ្ឋានជាទីអាស្រ័យនៅនៃមនុស្ស, ពិតសោតទៀតដែលនឹងតាំងនៅបាន ក៏ព្រោះ

តែអាស្រ័យកន្ទាយ, ការគ្រប់គ្រងចិញ្ចឹមកន្ទាយឲ្យឆាប់ធំមាំមួនខ្លាំងពូកែទៅបាន គឺព្រោះអាស្រ័យសេចក្តីព្យាយាមស្វែងរកអាហារសម្រាប់ទុកដើម្បីខ្លួន, កាលបើប្រាសចាកអាហារហើយ សន្តតិរូប គឺរូបដែលចំរើនជាប់តទៅក៏ឈប់ចំរើន ទាំងជីវិតសោតទៀត ក៏តាំងនៅបានដោយកម្រ ។ អាហារនេះជារបស់សំខាន់បំផុត សម្រាប់បម្រុងជីវិតឲ្យប្រព្រឹត្តទៅ សមដូចបាលីថា សព្វេ សត្តា អាហារដ្ឋិតិកា "ពួកសត្វពល់រូបដែលមានជីវិតរស់នៅបានក៏ព្រោះអាហារ" ។ វត្ថុឯទៀត ៗ ក្រៅពីអាហារនោះមានច្រើនប្រភេទណាស់ ដូចយ៉ាងលំនៅជាទីជ្រកកោនសំពត់សម្រាប់ស្លៀកដណ្តប់ ថ្នាំសម្រាប់កែរោគក្នុងពេលដែលត្រូវការប៉ុណ្ណោះជាដើម, វត្ថុទាំងអម្បាលនេះ សុទ្ធតែជារបស់ជួយឧបត្ថម្ភទប់ទល់ជីវិតទាំងអស់, បើប្រាសចាករបស់ណាមួយហើយ ជីវិតរមែងតាំងនៅដោយលំបាក ។

សូមទាញរឿងឧបមាខ្លះមកសំដែងក្នុងទីនេះ ឲ្យឃើញអានិសង្សនៃសេចក្តីព្យាយាម ។ យើងគួរយកតម្រាប់តាមសត្វកណ្តៀរ; កណ្តៀរជាសត្វមានខ្លួនតូចណាស់, តែកណ្តៀរមានសាមគ្គីធម៌ព្រមព្រៀងគ្នាព្យាយាមផ្ទួនដីបន្តិចម្តង ៗ រាល់ថ្ងៃ ក៏ពូនកើតឡើងទៅជាដំបូកមួយយ៉ាងធំ បានទៅជាផ្ទះសំបែងសម្រាប់គេជ្រកការពារញាតិមិត្តកូនចៅរបស់វាបានសេចក្តីសុខ-ចំរើន ឥតមានសត្រូវហានចូលលុកលុយបាន ទាំង

សម្បូរដោយគ្រឿងចិញ្ចឹមជីវិតរបស់វាឥតមានខ្វះខាត ។ មួយទៀត ដូចរុក្ខជាតិផ្សេង ៗ ជាជាតិមានដើមមានឫសខ្ចីទន់ខ្សោយកំឡាំងណាស់ តែបើរុក្ខជាតិទាំងនោះ ដុះទៅលើធម្មជាតិណាមួយមានធាតុរឹងប្រហែលនឹងថ្ម រុក្ខជាតិនោះ ទំរុលឫសប្រឹងចាក់ចូលសឹកសៀតបន្តិចម្តងៗ កាលថ្ងៃធម្មជាតិនោះ តស៊ូទននឹងរុក្ខជាតិពុំបាន ក៏របើករបេះប្រេះបែក ទៅដោយកំឡាំងព្យាយាមរបស់រុក្ខជាតិ រុក្ខជាតិក៏មានអំណាចចាក់ឫស ទៅដល់ផែនដីស្រូបយកកំឡាំងធាតុមកចិញ្ចឹមដើមរបស់វាឲ្យរឹងរឹតតែមានកំឡាំងខ្លាំងឡើង, នេះក៏មកអំពីសេចក្តីព្យាយាម ។

ម្យ៉ាងទៀត ដូចជាព្រះបរមពោធិសត្វព្រះនាមមហាជនក កាលលាមាតាចុះសំពៅទៅជួញជាមួយនឹងពួកឈ្មួញ, លុះដល់កណ្តាលមហាសមុទ្រ សំពៅក៏បែកធ្លុះធ្លាយទៅដោយខ្យល់ព្យុះខ្លាំង, ពួកឈ្មួញទាំងអស់ក៏មានសេចក្តីភិតភ័យតក់ស្លុតខ្លាចសេចក្តីស្លាប់, ខ្លះស្រែកទ្រហោយំ ខ្លះបន់ស្រន់ពួកទេព្តាអារក្សអ្នកតាឲ្យជួយស្រោចស្រង់ជីវិត, មិនសមប្រកបក៏លិចលង់ស្លាប់ក្នុងមហាសមុទ្រអស់ទៅ ។ ចំណែកខាងព្រះពោធិសត្វ មិនមានសេចក្តីភិតភ័យតក់ស្លុតនឹងសេចក្តីស្លាប់សោះឡើយ លោកនឹកដល់គុណមាតាបិតា គុណសីលធម៌ដែលលោកធ្លាប់បានប្រព្រឹត្តមកហើយ ក៏លោតចេញអំពីសំពៅប្រឹងហែលសំដៅទៅរកត្រើយ

ម្ពាន់អស់ចំនួន ៧ ថ្ងៃ  លុះដល់ថ្ងៃទី ៨ ជាថ្ងៃឧបោសថ  លោកក្រាបនូវឧបោសថសីល តាំងតែព្យាយាមហែលក្នុងកណ្ដាលមហាសមុទ្រ ។

ពេលនោះមានទេវធីតា ១ អង្គ ឈ្មោះមណីមេខលា  នៅរក្សាមហាសមុទ្រ , លុះឃើញព្រះបរមពោធិសត្វប្រឹងព្យាយាមហែលឥតមានឈប់ឈរ យ៉ាងនេះក៏ស្រែកសួរថា

កោយំ មជ្ឈេ សមុទ្ទស្មឹ អបស្សន្តីរមាយុហេ
កឹ ត្វំ អត្ថវសំ ញត្វា ឯវំ វាយាមសេ ភុសំ

អ្នកណានេះ  កាលបើមិនឃើញនូវកោះត្រើយសោះ ម្ដេចក៏ខំប្រឹងហែលក្នុងកណ្ដាលមហាសមុទ្រ, តើអ្នកដឹងនូវប្រយោជន៍ដូចម្ដេច  បានជាខំប្រឹងព្យាយាមហែលអ្វីម៉្លេះ?

ព្រះមហាជនកពោធិសត្វតបថា

និសម្ម វត្តំ លោកស្ស វាយាមស្ស ច ទេវតេ
តស្មា មជ្ឈេ សមុទ្ទស្មឹ អបស្សន្តីរមាយុហេ ។

ម្នាលទេវតា  ខ្ញុំពិចារណានូវវត្តនៃសត្វលោក  នឹងអានិសង្សនៃសេចក្ដីព្យាយាម, ព្រោះហេតុដូច្នោះ  ខ្ញុំបើទុកជាមិនឃើញនូវកោះត្រើយក៏ដោយចុះ  ក៏នៅតែប្រឹងព្យាយាមហែលក្នុងកណ្ដាលមហាសមុទ្រ (ទុកជាតម្រាប់ដល់លោក  ស្លាប់ពេលណា  ឈប់ពេលនោះ  មិនលះបង់នូវសេចក្ដីព្យាយាមទេ) ។

នាងទេពធីតាពោលថា

គម្ភីរេ អប្បមេយ្យស្មឹ តីរំ យស្ស នទិស្សតិ

មោឃោ តេ បុរិសវាយាមោ អប្បត្វាវ មរិស្សសិ

ត្រើយមហាសមុទ្រជ្រៅឆ្ងាយរកប្រមាណមិនបាន មិនប្រាកដដល់អ្នកណា ការព្យាយាមតាមកំឡាំងបុរស គឺជាការឥតអំពើដល់អ្នកនោះ អ្នកមិនដល់ត្រើយទេ មុខជានឹងស្លាប់ (ក្នុងមហាសមុទ្រនេះពុំខានឡើយ) ។

ព្រះបរមពោធិសត្វតបថា

អនណោ ញាតិនំ ហោតិ ទេវានំ បិតុនញ្ច សោ

ករំ បុរិសកិច្ចានិ ន ច បច្ឆានុតប្បតិ

(ម្នាលទេវតា) បុគ្គល (កាលកំពុងព្យាយាម សូម្បីនឹងស្លាប់) ក៏បានឈ្មោះថាជាអ្នកមិនមានបំណុល គឺថាពួកញាតិ ពួកទេវតា នឹងមាតាបិតាមិនតិះដៀលឡើយ , បុគ្គលនោះកាលបើបានធ្វើកិច្ចរបស់បុរសហើយ រមែងមិនក្ដៅក្រហាយឡើយក្នុងពេលជាខាងក្រោយ ។

នាងទេពធីតាពោលទៀតថា

អបារណេយ្យំ យំ កម្មំ អប្ផលំ កិលមថុទ្ទយំ

តត្ថ កោ វាយមេនត្ថោ មច្ចុ យស្សាភិនិប្បតំ

ការងារណាមិនសម្រេចដោយសេចក្ដីព្យាយាមទេ ការងារនោះទៅជារបស់ឥតផល មានតែសេចក្ដីលំបាកជាកម្រៃ, សេចក្ដីស្លាប់រមែង

សម្រេចផលបុគ្គលណា បុគ្គលនោះ នឹងមានប្រយោជន៍ដូចម្ដេច (ផលការ ព្យាយាមនោះ?)

ព្រះបរមគោធិសត្វតបទៅវិញថា

អចារណោយ៉ំ អច្ចន្តំ យេក វិធិត្វាន ទេវតេ
ឆរត្វ អត្តនោ ចាណំ ធញ្ញ សោ យតិ ហាបយេ
អធិប្បាយផលំ បកោ អស្មិំ លោកស្មិំ ទេវតេ
បយោជយន្តិ កម្មានិ តានិ វេជ្ជន្តិ ភ ណ ភ
សន្តិដ្ឋតំ កម្មផលំ ឆន្ទ បស្សសិ ទេវតេ
សន្ធា អញ្ញេ គភយន្តំ គញ្ញ បស្សាមិ សន្តិកេ
សោ អយំ ភយៈសំសង្ក យថាសតិ យថាពលំ
គច្ឆំ ចារំ សមុទ្ទស្ស កាលំ បុរិសការិយំ

ម្នាលទេវតា បុគ្គលណាដឹងច្បាស់ថា ការងារមានទីបំផុតក្រែពេក មិនគប្បីសម្រេចទេ ហើយលះបង់ចោលបែរផ្សារក្សាខ្លួនជីវិតរបស់ខ្លួនទៅវិញ ក៏បន្ថយនូវសេចក្ដីព្យាយាមចោលចេញ, បុគ្គលនោះគង់ដឹងនូវផលនៃសេចក្ដីខ្ជិលច្រអូសនោះពុំខាន ឡើយ ។ ម្នាលទេវតា បុគ្គលពួកខ្លះក្នុងលោកនេះ កាលបើឃើញនូវផលនៃសេចក្ដីប្រាថ្នាហើយ រមែងប្រកបនូវការងារទាំងឡាយ ការងារទាំងនោះទោះបីសម្រេចក្ដីមិនសម្រេចក្ដី គួរតែខំប្រឹងព្យាយាមកុំខាន ។ ម្នាលទេវតា ក្រែងអ្នក

បានឃើញនូវផលនៃសេចក្ដីព្យាយាមដ៏ជាក់ច្បាស់ដោយខ្លួនឯងដែរឬ ? ជនទាំងឡាយឯទៀត ៗ លិចចុះក្នុងមហាសមុទ្រអស់ហើយ មកពីមិនមានសេចក្ដីព្យាយាម ៗ ឯខ្ញុំតែម្នាក់ឯងទេដែលកំពុងហែលក្នុងមហា-សមុទ្រ ទាំងបានឃើញអ្នកដែលស្លាប់នៅក្នុងទីជិតខ្ញុំ ខ្ញុំនេះខឹងព្យាយាមតាមសមគួរដល់សេចក្ដីអង់អាច ទើបសមគួរដល់កំលាំង កាលបើខ្ញុំបានដល់ត្រើយនៃមហាសមុទ្រហើយ ខ្ញុំនឹងធ្វើនូវសេចក្ដីព្យាយាមដែលបុរសគប្បីធ្វើនោះឲ្យសម្រេចជាក់យថាភាព ៗ

នាងទេពធីតាបានស្ដាប់ព្រះមហាជនកពោធិសត្វហើយ ក៏ពោលសរសើរថា ៗ

យោ ត្វំ ឯវំ គតេ ឱឃេ អប្បមេយ្យេ មហណ្ណវេ
ធម្មវាយាមសម្បន្នោ កម្មុនា នាវសីទសិ
សោ ត្វំ តត្ថ គច្ឆាហិ យត្ថ តេ អភិរតោ មនោ

កាលបើមហាសមុទ្រមានអន្លង់ទឹកជំរៅជ្រៅប្រមាណមិនបាន ប្រព្រឹត្តទៅយ៉ាងនេះ អ្នកណាប្រកបដោយសេចក្ដីព្យាយាមដោយធម៌ រមែងមិនលិចចុះដោយកម្មគឺសេចក្ដីព្យាយាមឡើយ ចិត្តរបស់អ្នកត្រេកអរក្នុងទីណា អ្នកនោះចូលទៅក្នុងទីនោះចុះ ៗ

នាងទេពធីតាពោលសរសើរតែប៉ុណ្ណេះហើយ ក៏ស្ទុះទៅចាប់ដើមដៃព្រះពោធិសត្វកើចទាញនាំយកទៅដាក់ដល់មិថិលានគរនោះឯង ៗ

នាំរឿងរ៉ាវមកប៉ុណ្ណេះឲ្យឃើញថា គុណសម្បត្តិនៃសេចក្តីព្យាយាម នេះ អាចឲ្យសម្រេចផលបុគ្គលអ្នកមានសមត្ថភាព គឺភាពនៃសេចក្តីអង់អាច សេចក្តីមោះមុត, សមត្ថកាល វេលាដែលនៅប្រឹងបាន នៅធ្វើការកើត កំពុងពេញកំឡាំងនៅឡើយ ។ បុគ្គលណាកាលបើមានសេចក្តីពេញចិត្តក្នុងការបំពេញកិច្ចរបស់ខ្លួនយ៉ាងនេះហើយ បុគ្គលនោះបើទុកជាស្លាប់ក្នុងពេលកំពុងព្យាយាមបំពេញកិច្ច, ក៏បានឈ្មោះថាប្រសើរបំផុត ។ ខ្លួនស្លាប់បាត់ទៅមែន តែកេរ្តិ៍ឈ្មោះនៅល្អ, ខ្លួនស្លាប់ទៅចុះ កុំឲ្យតែស្លាប់សេចក្តីព្យាយាម ។ សមដូចពុទ្ធភាសិតថា រូបំ ជីយ្យតិ មច្ចានំ នាមគោត្តំ ន ជីយ្យតិ រូបនៃសត្វទាំងឡាយរមែងស្លាប់ទៅ តែនាមនឹងគោត្រមិនស្លាប់ឡើយ ។ វីរិយេន ទុក្ខម-ច្ចេតិ ជនរមែងរួចសេចក្តីទុក្ខបានដោយសេចក្តីព្យាយាម ។

សំដែងអំពីបញ្ញាសជាតកចប់តែប៉ុណ្ណេះ ។ សូមផ្សាយចំណែកកុសលផលដល់ពុទ្ធសាសនិកជនទាំងឡាយក្នុងកម្ពុជរដ្ឋទាំងមូលឲ្យបានសេចក្តីសុខ-ចំរើនគ្រប់ប្រការ ។

ទុក្ខរោគភយា វេរា សោកា សត្តុចុបទ្ទវា
អនេកា អន្តរាយាបិ វិនស្សន្តុ ច តេជសា

សេចក្តីទុក្ខ ទីនរោគ ទីនភ័យ ទីនពៀរទាំងឡាយក្តី សេចក្តីសោក ទីនសត្រូវ ទីនឧបទ្រពទាំងឡាយក្តី អន្តរាយទាំងឡាយដ៏ច្រើនក្តី សូមឲ្យវិនាសបាត់ទៅ ដោយតេជៈ (នៃធម្មទេសនានេះ), ។

**ចប់ បញ្ញាសជាតកតែប៉ុណ្ណេះ ។**